# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ......០៧៣.............ធ. ធ. ស(ប្រក)

## ប្រកាស

### ស្តីពីការបង្កើតថ្នាក់ពុទ្ធិកមធ្យមសិក្សាទុតិយភូមិ នៅពុទ្ធិកវិទ្យាល័យខេមរង្សី វត្តអារញ្ញិការាម

****

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ ន.ស.រ.ក.ត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២.នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ នឹងប្រព្រឹត្តទៅ របស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស.រកម.០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងធម្មការ និង សាសនា
- យោងសំណើសុំបើកថ្នាក់ពុទ្ធិកមធ្យមសិក្សាទុតិយភូមិ លេខ ៣៤២ មធស.ក.ធ ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៣ របស់មន្ទីរធម្មការ និងសាសនា ខេត្តកំពង់ឆ្នាំង
- យោងចំណារឯកភាព លេខ ១១១២ ស.រ.ស.ល ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៣ របស់អភិបាលខេត្តកំពង់ឆ្នាំង .

## សម្រេច

<u>ប្រការមួយ</u> : បង្កើតថ្នាក់ពុទ្ធិកមធ្យមសិក្សាទុតិយភូមិនៅ ពុទ្ធិកវិទ្យាល័យខេមរង្សី វត្តអារញ្ញិការាម ខេត្តកំពង់ឆ្នាំង ។

<u>ប្រការ ២</u> : ពុទ្ធិកវិទ្យាល័យខេមរង្សី វត្តអារញ្ញិការាម ជាគ្រឹះស្ថានពុទ្ធិកសិក្សា ស្ថិតនៅក្រោមការដឹកនាំ របស់មន្ទីរធម្មការ និង សាសនាខេត្តកំពង់ឆ្នាំង និងការណែនាំមុខជំនាញបច្ចេកទេស របស់អគ្គនាយកដ្ឋានពុទ្ធិកសិក្សា នៃក្រសួងធម្មការនិងសាសនា

<u>ប្រការ ៣</u> : ពុទ្ធិកវិទ្យាល័យនេះ ត្រូវចាប់បើកថ្នាក់ពុទ្ធិកមធ្យមសិក្សាទុតិយភូមិ ពីឆ្នាំសិក្សា ២០០៤-២០០៥ តទៅ ។

<u>ប្រការ ៤</u> : ខុទ្ទកាល័យ អគ្គនាយកដ្ឋានពុទ្ធិកសិក្សា នាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ការិយាល័យបុគ្គលិក និងមន្ទីរធម្មការ និង សាសនា ខេត្តកំពង់ឆ្នាំង មានភារកិច្ចរៀងៗខ្លួន អនុវត្តន៍សេចក្តីប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ចម្លងប្រគេន-ជូន**

- ថ្វាយសម្តេចព្រះសង្ឃរាជទាំងពីរគណៈ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងអប់រំយុវជន និង កីឡា
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- សាលាខេត្តកំពង់ឆ្នាំង
  "ដើម្បីថ្វាយ ជូនជ្រាបជាពត៌មាន"
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"

រាជធានីភ្នំពេញ.ថ្ងៃទី២០ ខែ កុម្ភៈ ឆ្នាំ ២០០៤

រដ្ឋមន្ត្រី

ជា-សាវឿន